ការដែលគ្រូនិយាយសំដៅទៅចំណេះដឹងពីមុនរបស់សិស្សគឺបទពិសោធក្នុងសហគមន៍ និង កាសិក្សាពីមុនដែលជាប់ពាក់ព័ន្ធគឺជារឿងសំខាន់ណាស់ក្នុងការបង្រៀនគ្រប់យ៉ាង ។ ហេតុផលចំពោះរឿងនេះគឺបង្កលក្ខណៈងាយស្រួលមួយសំរាប់ចំណេះដឹងថ្មី ដែលអ្នកប្រុងប្រៀបនឹងបង្រៀន ។ ការរៀនគឺជាកាសន្សំប្រមូល (ធ្វើអោយមានការប្រែប្រួល) ហើយប្រសិនបើការចងចាំរបស់សិស្សនូវអ្វីដែលគេបានដឹងកន្លងមក អំពីមេរៀននោះត្រូវបានបំផុសមុនពេលគេរៀនខ្លឹមសារ រឺមេរៀនថ្មីទៀតនោះគេនឹងត្រៀមលក្ខណៈល្អទៀតក្នុងការទទួលមេរៀនថ្មីនោះ ។

តាមពិតការបង្កលក្ខណៈសំរាប់ចំណេះដឹងថ្មីគឺជាការងារធម្មតាទេ ។ អ្នកតែងធ្វើវារៀងរាល់ថ្ងៃកាលណាអ្នកនឹងប្រាប់អ្វីមួយដល់គេឯង ។ ចូរអ្នកពិនិត្យមើលឧទាហរណ៍នេះ :

" អ្នកស្គាល់សុផល ដែលមកពីកំពង់ធំមែនទេ ? អូ ! គាត់ទើបតែភ្ជាប់ពាក្យជាមួយផល្លា"

ការដែលនិយាយថា "អ្នកឯងស្គាល់សុផល...........?" គឺថាអ្នកកំពុងបង្កលក្ខណៈសំរាប់ធ្វើអ្វីដែលអ្នកនឹងនិយាយនោះហើយ ។ ប្រសិនបើអ្នកមិនធ្វើបែបនេះទេ មិត្តដែលកំពុងនិយាយជាមួយនោះ នឹងសួរថា "សុផលជាអ្នកណា ?" បានសេចក្តីថា មិត្តអ្នកអាចមានការច្រឡំអំពីអ្នកណាដែលអ្នកចង់និយាយ នោះហើយអាចជាការយល់ច្រឡំក៏មានដែរ ។

ជាការសំខាន់ណាស់ដែលធ្វើបែបនេះក្នុងថ្នាក់របស់អ្នក ជួនកាលវានឹងមានប្រយោជន៍ ការដែលនិយាយដោយផ្ទាល់ទៅមេរៀនមុនមួយ (ការរំលឹកមេរៀនមុនមួយ ) ប៉ុន្តែការនេះមិនមែនសុទ្ធតែចាំបាច់រហូតនោះទេ ។ ជាញឹកញាប់កាលណាប្រាប់រឺបង្រៀនគំនិតសេចក្តីរឺមេរៀនថ្មីមួយ អ្នកគប្បីផ្សារភ្ជាប់គំនិត សេចក្តីនេះជាមួយនឹងអ្វីមួយដែលសិស្សធ្លាប់បានដឹងមកហើយក្នុងជីវិតរស់នៅក្រៅសាលារបស់ពួកគេ។ ការនេះធ្វើអោយប្រធានបទដែលនឹងបង្រៀនមានការផ្សារភ្ជាប់ បង្កើតចំណាប់អារម្មណ៍ទៅលើវា និង បង្កើតស្ថានភាពមួយដែលសិស្សចង់ស្វែងយល់កាន់តែខ្លាំងទៀត ។

**ឯកសារទី២៥: ការអាន"ការប្រើប្រាស់ភាសារបស់កុមារ-អំពីកង់"** (ដកស្រង់ពីឯកសារជួយសិស្សខ្សោយស្របពេលសិក្សា និង វិធីបង្រៀន-រៀនតាមលំនាំបច្ចេកទេសទាំង៤ ទំព័រ២២)

ថ្ងៃទី៧ ដំណាក់កាលបង្រៀនទី១០

+ ***វត្ថុបំណង*** : អភិវឌ្ឍលើការពង្រឹងភាសាដែលកុមារធ្លាប់បានប្រើប្រាស់ឱ្យចូលរួមរៀបចំអត្ថបទដោយតំរង់ចំណេះដឹងទាំងនេះមកលើមុខវិជ្ជាជាច្រើនតាមរយៈសង្កេត ពិភាក្សា និង សំណេរ បានត្រឹមត្រូវ ។
+ ***សម្ភារ*** : កន្ទេលឬកំរាល , ទោចក្រយាន ( កង់ ) ។
+ ***វិធីបង្រៀន*** :

- ចែកសិស្សជាក្រុម
- ណែនាំអោយសិស្សត្រៀមសៀវភៅ ប៊ិច តាមដៃគូក្នុងក្រុមដើម្បីកត់ត្រា ។
- នាំសិស្សចេញក្រៅថ្នាក់ (ឱ្យមានកំរាល) អង្គុយតាមក្រុម ដើម្បីសង្កេតទោចក្រយាន ( កង់) មួយ គ្រឿង ។
- ណែនាំឱ្យសិស្សស្រង់ព័ត៌មានដោយកត់ត្រានូវគ្រប់ចំណុចដែលគេបានមើលឃើញជាក់ស្តែងតាមដៃគូ តាមរយៈក្រុមរបស់ពួកគេ ( រយៈពេល១០នាទី) ។
- បំផុសសំណួរបន្ថែម ដើម្បីអោយសិស្សផ្តោតលើការបង្ហាញតាមបែបលក្ខណៈវិទ្យាសាស្ត្រ-តាមបែបលក្ខណៈគណិតវិទ្យា ... ។
- ឱ្យសិស្សចូលក្នុងថ្នាក់វិញ រួចឱ្យសរសេរការពណ៌នាទោចក្រយាន ( កង់) តាមដៃគូក្នុងក្រុម ។
- ឱ្យសិស្សតាមដៃគូក្នុងក្រុមអានកិច្ចការរបស់គេ (អានខ្សឹប) រួចឆ្លងក្នុងក្រុមដើម្បីជ្រើសរើសអត្ថបទមួយដែលល្អសំរាប់ក្រុម ។
- ឱ្យតំណាងសិស្សក្នុងក្រុមឡើងរាយការណ៍ ( ម្តងមួយក្រុម) ។
- គ្រូ និង សិស្សសំយោគវាយតម្លៃរកក្រុមដែលពណ៌នាបានល្អ ។

## ឯកសារទី២៦: កញ្ចប់សម្ភាររបស់គ្រូសហគមន៍-បញ្ជីខ្ចីមសារ

ថ្ងៃទី៨ ដំណាក់កាលបង្រៀនទី១

| លរ | សម្ភារ | ចំនួន |
|---|---|---|
| ១ | កាតាប | ១ |
| ២ | ប្រដាប់កិបក្រដាស | ១ |
| ៣ | គ្រាប់កិប | ១ ប្រអប់ |
| ៤ | គូល័រទៀន | ២ ប្រអប់ |
| ៥ | ហ្វឹតក្រដាសពណ៌ខ្មៅ | ៣ ដើម |
| ៦ | ហ្វឹតក្រដាសពណ៌ក្រហម | ៣ ដើម |
| ៧ | ទឹកហ្វឹតក្រដាសពណ៌ខ្មៅ | ១ ដប |
| ៨ | ទឹកហ្វឹតក្រដាសពណ៌ក្រហម | ១ ដប |
| ៩ | ប៊ិចខៀវ | ២ ដើម |
| ១០ | ក្រដាសរ៉ាមអាកាត់ | ១ រ៉ាម |
| ១១ | កាវទឹក | ១ ដប |
| ១២ | ស្កុតក្រដាស | ១ ដុំ |
| ១៣ | ដែកគោលវាយជញ្ជាំង | ២ កញ្ចប់ |
| ១៤ | អក្សរចល័ត | ១ ឈុត |
| ១៥ | កៅស៊ូកង | ២ ខាំ |
| ១៦ | បំពង់បឺត | ៣00 ដើម |
| ១៧ | សៀវភៅសរសេរ ១២0ទំព័រ | ៤ ក្បាល |
| ១៨ | ក្រដាសរ៉ាមធំ | ១0 សន្លឹក |
| ១៩ | ក្រដាសកាតុង | ៥ សន្លឹក |
| ២0 | ខ្សែនីឡុង | ៥0 ម |
| ២១ | បញ្ជីស្រង់ពិន្ទុ | ១ ក្បាល |
| ២២ | បញ្ជីហៅឈ្មោះសិស្ស | ១ ក្បាល |
| ២៣ | ផែនទីប្រទេសកម្ពុជា | ១ សន្លឹក |
| ២៤ | ផែនទីពិភពលោក | ១ សន្លឹក |
| ២៥ | តារាងអក្ខរក្រម | ១ សន្លឹក |
| ២៦ | តារាងចំនួន (ខ្មែរ) | ១ សន្លឹក |
| ២៧ | តរាងចំនួន (អារ៉ាប់) | ១ សន្លឹក |
| ២៨ | ក្រណូ | ១ |

**ឯកសារទី២៧: ល្បែងសិក្សាសំរាប់មុខវិជ្ជាគណិតវិទ្យា**

ថ្ងៃទី៨ ដំណាក់កាលបង្រៀនទី៣

| លរ | ប្រភេទល្បែង | ការបរិយាយនៃល្បែង |
|---|---|---|
| ១ | | |
| ២ | | |
| ៣ | | |
| ៤ | | |
| ៥ | | |
| ៦ | | |
| ៧ | | |
| ៨ | | |
| ៩ | | |
| ១០ | | |
| ១១ | | |
| ១២ | | |
| កំណត់សំគាល់ផ្សេងៗ | | |

**ឯកសារទី២៨: ល្បែងសិក្សាសំរាប់មុខវិជ្ជាភាសាខ្មែរ**

ថ្ងៃទី៨ ដំណាក់កាលបង្រៀនទី៤

| លរ | ប្រភេទល្បែង | ការបរិយាយនៃល្បែង |
|---|---|---|
| ១ | | |
| ២ | | |
| ៣ | | |
| ៤ | | |
| ៥ | | |
| ៦ | | |
| ៧ | | |
| ៨ | | |
| ៩ | | |
| ១០ | | |
| ១១ | | |
| ១២ | | |
| កំណត់សំគាល់ផ្សេងៗ | | |

## ឯកសារទី២៩: Dimensions ទាំង៦នៃសាលាកុមារមេត្រី និងសេចក្តីបរិយាយនៃផ្នែកនីមួយៗ

ថ្ងៃទី៩ ដំណាក់កាលបង្រៀនទី២

**១- អ្វីទៅហៅថាសាលាកុមារមេត្រី ?**

សាលាកុមារមេត្រី គឺជាសាលាដែលអនុវត្តកម្មវិធីផ្អែកលើសិទ្ធិកុមារជាមូលដ្ឋានដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធក្នុងការបង្កើតបរិស្ថានរៀនសូត្ររបស់សិស្សប្រកបដោយសាមគ្គីភាព សេរីភាព សមភាព សមធម៌ គ្មានអំពើហឹង្សា មានផាសុខភាពផ្លូវកាយ ផ្លូវចិត្ត ប្រាជ្ញា សំដៅអភិវឌ្ឍចំនេះដឹង បំណិន សីលធម៌ ចេះរួមរស់ជាមួយគ្នាដែលជាការឆ្លើយតបទៅនឹងការរស់នៅជាក់ស្តែងរបស់ពួកគេជាពិសេសផ្តោតលើការស្វែងរកកុមារអោយបានចូលរៀនគ្រប់គ្នា និងការសិក្សាតាមតំរូវការរបស់សិស្សប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ។

**គោលការណ៍អនុវត្ត**

ដើម្បីសំរេចនៃគោលបំណងខាងលើនេះ ការអនុវត្តកម្មវិធីសាលាកុមារមេត្រីត្រូវផ្អែកលើសមាសភាគទាំង៦ដូចខាងក្រោម :

**១- កុមារទាំងអស់បានចូលរៀន**

ការអប់រំបញ្ចូលគ្នា គឺជាការផ្តល់ឱកាសសំរាប់កុមារទាំងអស់អោយទទួលបានការអប់រំប្រកបដោយសមធម៌ ។

**ខ្លឹមសារ និង សកម្មភាពអនុវត្ត :**

**១-១ ការគ្រប់គ្រងទិន្នន័យព័តិមាន :**

- ប្រមូលចងក្រងស្ថិតិព័តិមានកុមារតាមគ្រួសារ ដូចជាកុមារជួបការលំបាកដោយប្រការផ្សេងៗតាមភូមិនីមួយៗតាមរយៈការប្រើបណ្តាញផែនទីសិក្សា ។
- រៀបចំយុទ្ធនាការប្រមូល និងទទួលចុះឈ្មោះកុមារចូលរៀនដោយមានការទទួលខុសត្រូវតាមមុខសញ្ញាដែលបានចាត់តាំង ។

**១-២ ការគ្រាំទ្រ :**

- រៀបចំបរិស្ថានសាលារៀនអោយមានសោភ័ណភាពដើម្បីទាក់ទាញសិស្សចូលរៀនប្រកបដោយគុណភាព ។
- កសាងជំរាលនៅមុខថ្នាក់រៀនដើម្បីសំរួលដល់សិស្សពិការ
- រៀបចំសួនកុមារសំរាប់សិស្សពិការដើម្បីពង្រឹងនូវកាយសម្បទា សតិបញ្ញា ស្មារតី អោយបាន រឹងមាំ ។
- បង្កើតសាលារៀនកំរិតអប់រំមូលដ្ឋាននៅថ្នាក់ឃុំ ។
- រៀបចំថ្នាក់ / សាលាឆ្លងកាត់ និងថ្នាក់សង្គ្រោះបន្ទាន់ដើម្បីជួយសំរួលដល់សិស្សនៅផ្ទះឆ្ងាយសិស្សមានអាយុច្រើនបានចូលរៀននៅបឋមសិក្សា ។
- រៀបចំថ្នាក់បំប៉នបន្ថែមសំរាប់សិស្សរៀនយឺតស្របពេលក្នុងថ្នាក់ និងតាមខ្នងផ្ទះ ពិសេសថ្នាក់ទី ១ និង ទី ២ ។

- រៀបចំថ្នាក់បញ្ចើដើម្បីទទួលសិស្សទៅតាមឪពុកម្តាយចល័តមុខរបរអោយចូលរៀនតាមកំរិតថ្នាក់ ដែលនៅជិតកន្លែងប្រកបមុខរបរតាមរយៈកម្មវិធីគ្រូបង្រៀនចល័ត ថ្នាក់គួប... ។
- រៀបចំកម្មវិធីបំណិនជីវិត កម្មវិធីអាហាររូបករណ៍សិស្សក្រីក្រ អាហាររូបបត្ថម្ភ និង កម្មវីធី បញ្ជូនកុមារទៅព្យាបាល... ។

## ២- ការសិក្សាប្រកបដោយប្រសិទ្ធភាព

ប្រសិទ្ធភាពនៃការសិក្សាគឺជាសកម្មភាពរៀន និង បង្រៀនក្នុងបរិយាកាសសប្បាយរីករាយ ប្រកបដោយគុណភាព និង សមធម៌ ។

**ខ្លឹមសារ និង សកម្មភាពអនុវត្ត :**

**២-១- ការពង្រឹងលើការងារគ្រប់គ្រងបច្ចេកទេស :**

- ពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងបច្ចេកទេសតាមរយៈប្រធានក្រុមបច្ចេកទេសតាមកំរិតថ្នាក់របស់សាលារៀន និងកំរងព្រមទាំងរៀបចំបំណែងចែកកម្មវិធីសិក្សា និងអនុវត្តអោយមានប្រសិទ្ធិភាព ។
- ប្រមូលទិន្នន័យអំពីការបង្រៀន-រៀនតាមរយៈការចុះវាយតំលៃ ( អធិការកិច្ច ) ដើម្បីជួយអោយទាន់ពេលវេលា ។

**២-២- ការបង្រៀន - រៀន**

- សំរបសំរួលខ្លឹមសារមេរៀននៃមុខវិជ្ជាទាំង ៤ជាគោលអោយស្របតាមសមត្ថភាពសិស្ស ។
- ពង្រឹងការអនុវត្តការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល តាមរយៈបច្ចេកទេសទាំង៤ និងការប្រើសំណួរ Taxonomy.
- ពង្រឹងការសិក្សាផ្សារភ្ជាប់ជីវភាពពិតជាក់ស្តែងអោយបានញឹកញាប់ ( ឧ: ការចុះពិនិត្យកន្លែងចិញ្ចឹមសត្វ ដាំបន្លែ... ) ។
- បង្កើតអោយមានការប្រជុំបច្ចេកទេស ទស្សនៈកិច្ចសិក្សាដើម្បីផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមក ។

**២-៣- ធនធាន :**

- រៀបចំបណ្ណាល័យ រោងជាង គេហកិច្ច សួនច្បារ សួនជីវចំរុះ សួនកសិកម្ម ទីលានកីឡា បរិស្ថានធម្មជាតិ មណ្ឌលវប្បធម៌ សួនកុមារ ... ។
- ផលិតសំភារៈឧបទេសងាយៗដែលត្រូវបង្រៀន និងរៀន និងសំភារៈដែលបានមកពី បរិស្ថាន ... ។

**២-៤- កម្មវិធីគាំទ្រ :**

- ការពង្រឹងកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ( ចិញ្ចឹមសត្វ ដាំដំណាំ គេហកិច្ច ... ។
- អនុវត្តកម្មវិធីអប់រំកុមារអាយុ ៦ ឆ្នាំ ដែលមិនបានឆ្លងកាត់មត្តេយ្យសិក្សារៀនថ្នាក់ទី១នៅសាលាបឋមសិក្សា ។

## ៣- សុខភាព សុវត្ថិភាព និង ការការពារកុមារ

សុខភាព សុវត្ថិភាព និងការការពារដល់កុមារគឺជាការយកចិត្តទុកដាក់គាំទ្រ ការការពារពីគ្រប់មជ្ឈដ្ឋានដើម្បីអោយកុមារមានការអភិវឌ្ឍន៏កាយសម្បទា សតិ បញ្ញាស្មារតី និង សញ្ចេតនា ប្រកបដោយផាសុខភាព ។

**ខ្លឹមសារ និង សកម្មភាពអនុវត្ត :**

**៣-១- សុខភាព :**

- អនុវត្តកម្មវីធីអប់រំកាយ និងកីឡាព្រមទាំងណែនាំពីររបៀប ហូបស្អាត ផឹកស្អាត រស់នៅស្អាត ជាប្រចាំ ។

- បង្កើតអោយមានហឹបសង្គ្រោះបឋម ព្រមទាំងធ្វើទំនាក់ទំនងជាមួយមណ្ឌលសុខភាពដើម្បីចុះផ្សព្វផ្សាយអំពីកម្មវិធីអប់រំសុខភាព និងអាហារូបត្ថម្ភ ។
- ជំរុញឪពុកម្តាយសិស្សអោយយកចិត្តទុកដាក់គិតគូរអំពីអាហារពេលព្រឹកសំរាប់កូនចៅមុនពេលទៅសាលារៀន ។

**៣-២- សុវត្ថិភាព និង ការការពារ :**

- អប់រំជាប្រចាំអោយគេយល់ដឹងអំពីសុវត្ថិភាព ចំណីអាហារ ភេសជ្ជៈ ច្បាប់ចរាចរ ល្បែងដែលនាំអោយគ្រោះថ្នាក់ ការគ្រោះថ្នាក់ដោយគ្រឿងញៀន និងអោយពួកគេធ្វើពលកម្ម ហាត់កីឡា និងអនាម័យផ្សេងៗ ។

## ៤- ការឆ្លើយតបនឹងយេនឌ័រ

ការធានានូវយេនឌ័រ គឺជាការកំណត់តួនាទី និងការទទួលខុសត្រូវរបស់កុមារីក្នុងសាលារៀនក្នុងសង្គមប្រកបដោយសមភាព និងសមធម៌ ។

**ខ្លឹមសារ និង សកម្មភាពអនុវត្ត :**

**៤-១- ការបញ្ជ្រាបខ្លឹមសារយេនឌ័រ :**

- បំណិនខ្លឹមសារគ្រប់សកម្មភាពអប់រំ

**៤-២ ការឧបត្ថម្ភ និង គាំទ្រក្នុងការ ចូលរួមពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធ :**

- រៀបចំកម្មវិធីគេហកិច្ច កម្មវិធីឧបបត្ថម្ភដល់កុមារក្រីក្រ និងរៀបចំកម្មវិធីអាហារូបករណ៍ដល់សិស្សក្រីក្រទូទៅ .. ។
- បង្កើតអោយមានបង្គន់អនាម័យដោយឡែកសំរាប់កុមារីនិងកម្មវីធីបំណិនជីវិតសំរាប់សិស្សទាំងអស់គ្នា ។
- រៀបចំស្ថិតិអំពីការរៀនខ្សោយ ត្រួតថ្នាក់ បោះបង់ការសិក្សារបស់សិស្សស្រី

## ៥- ការចូលរួមរបស់កុមារ គ្រួសារ និង សហគមន៍

ការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍គឺជាការធ្វើទំនាក់ទំនងសហការយ៉ាងចុះសំរុងគ្នា ។

**ខ្លឹមសារ និង សកម្មភាពអនុវត្ត :**

**៥-១ ការចូលរួមពីសិស្ស :**

- សាលានីមួយៗរៀបចំអោយមានក្រុមប្រឹក្សាកុមារ ក្លឹបសិក្សាតាមសាលារៀន តាមភូមិ ព្រមទាំងរៀបចំអោយមានការពិព័ណ៌ស្នាដៃសិស្ស កម្មវិធីសរសេរកំរងស្នាដៃសិស្សអំពីប្រវត្តិផ្សេងៗឬបទពិសោធន៍ល្អក្នុងសហគមន៍ និងកម្មវិធីលើកស្ទួយការយល់ដឹងពីវប្បធម៌ ប្រពៃណី សាសនា តាមតំបន់ ។

**៥-២ ការចូលរួមពីគ្រួសារ**

- សាលារៀននីមួយៗរៀបចំអោយគ្រួសារសិស្សចូលរួមទស្សនៈកិច្ចសាលារៀននិងគ្មានកម្មវិធីស្វ័យសិក្សាកូននៅផ្ទះដើម្បី ជំរុញអោយកូនទៅសាលារៀនបានទៀងទាត់ព្រមទាំងកម្មវិធីជួយដល់គ្រួសារសិស្សដែលយ៉ាប់យ៉ឺន ទីទ័លក្រ និង គ្រូដែលជួបការលំបាក ។

**៥-៣ ការចូលរួមរបស់សហគមន៍ :**

- សាលារៀននីមួយៗរៀបចំអោយមានការចូលរួមរបស់សហគមន៍ក្នុងបណ្តាញក្រុមការងារតាមភូមិ ការធ្វើជំរឿនស្ថិតិកុមារ ការប្រមូលកុមារចូលរៀន ការសាងសង់ ជួសជុល និងជួយការពារសាលារៀន ។
- ផ្តល់បទពិសោធន៍ដល់កុមារតាមជំនាញផ្សេងៗ ។

- បង្កើតហិបប្រាក់តាមវត្តតាមភូមិដើម្បីជួយកុមារក្រីក្រជួបការលំបាកក្នុងការសិក្សា ។

**៦- ការគាំទ្រកម្មវិធីពីប្រព័ន្ធអប់រំ**

ការគាំទ្រពីប្រព័ន្ធគ្រប់គ្រងអប់រំ គឺជាយន្តការការងាររបស់ប្រព័ន្ធគ្រប់គ្រងអប់រំដែលធ្វើអោយកម្មវិធីមានដំណើរការប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ។

**ខ្លឹមសារ និង សកម្មភាពអនុវត្ត :**

**៦-១ រៀបចំនិងពង្រឹងរចនាសម្ព័ន្ធ :**

- រៀបចំក្រុមការងារទទួលខុសត្រូវគ្រប់លំដាប់ថ្នាក់ព្រមទាំងពង្រឹងស្ថានភាពដល់គណៈកម្មការដែលមានស្រាប់ ។
- រៀបចំឯកសារ និងឧបករណ៍ផ្សេងៗសំរាប់អនុវត្តការងារ ។

**៦-២ ការកសាងសមត្ថភាពលំដាប់ថ្នាក់**

- រៀបចំបំប៉នបច្ចេកទេសកម្មវិធីសាលាកុមារមេត្រីអោយដល់អ្នកដែលពាក់ព័ន្ធ ។
- ដោះស្រាយ និងផ្លាស់ប្តូរបទពិសោធន៍ បញ្ហាដែលកើតមាន ។
- ទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍ដើម្បីជួយរវាងសាលាដៃគូកំរងដៃគូ និងស្រុកដៃគូ ... ។

**៦-៣ ការផ្តល់ថវិកា និង ធនធាន :**

- លើកទឹកចិត្ត និងផ្តល់សំភារៈ ថវិកា គាំទ្រដំណើរការសាលារៀន ។
- ស្វែងរកមូលនិធិពីប្រភពផ្សេងៗដើម្បីទ្រទ្រង់សាលារៀន ។

**៦-៤ ការងារតាមដានវាយតំលៃ :**

- រៀបចំបណ្តាញធ្វើការងារអធិការកិច្ចជួយគ្រូ ដោយប្រើឧបករណ៍ និងមានលក្ខណៈវិនិច្ឆ័យច្បាស់លាស់សំរាប់វាស់លទ្ធផលការងារសាលាកុមារមេត្រី ។
- បូកសរុបលទ្ធផលការងារ និង ផែនការអនុវត្តបន្ត ... ។

សាលាកុមារមេត្រី ( ប្រយោគបំបែក)

ចំរៀក១/២:

យើងមានទីធ្លាសាលារៀនស្អាតប្រកបដោយសុវត្ថិភាព និង មានទឹកស្អាត...........................................

សំរាប់ហូប និងលាងដៃ ។

ចំរៀក៣/៤:

សិស្សមានសុខភាពល្អ និងរក្សាសុខភាព...........................................................

ដោយលេងកីឡាផ្សេងៗ ។

ចំរៀក៥/៦:

កុមារទាំងអស់នៅក្នុងសហគមន៏អាចទៅ.................................................................

រៀនប្រកបដោយសុវត្ថិភាព ដោយមិនគិតអំពីភេទ ពិការភាព ឬក៏ភាសាដែលគេនិយាយ ។

ចំរៀក៧/៨:

ទីកន្លែងដែលកុមាររៀនជា.....................................................

កន្លែងដែលធ្វើអោយពួកគេសប្បាយ ។ កុមារចូលចិត្តទៅសាលារៀន ពីព្រោះមានសកម្មភាពគួរអោយចាប់អារម្មណ៍ ទាំងក្នុងថ្នាក់ និងក្រៅថ្នាក់រៀន ។

ចំរៀក៩/១០:

គ្រូទាំងអស់នៅតាមសាលារៀនបង្ហាញគំរូល្អដល់.........................................................

កុមារា និង កុមារី ។

ចំរៀក១១/១២:

ឳពុកម្តាយ និងក្រុមគ្រួសារ................................................

ជាផ្នែកមួយនៃការសិក្សារបស់កូន ។

ចំរៀក១៣/១៤:

យើងអោយឳពុកម្តាយ និងក្រុមគ្រួសារយើងចូលរួមក្នុង......................................................

សកម្មភាពរៀនសូត្រប្រចាំថ្ងៃរបស់យើងហើយយើងអញ្ជើញគាត់ចូលរួមក្នុងព្រឹត្តិការណ៍សំខាន់ៗរបស់សាលាយើង ។

ចំរៀក១៥/១៦:

កុមារា និងកុមារី មានឳកាសស្មើគ្នាក្នុងការចូលរៀននិងនៅរៀនបន្តអោយចប់............................................

យ៉ាងហោចណាស់ដល់ថ្នាក់ទី៩ ។

ចំរៀក១៧/១៨:

កុមារចាប់ពីអាយុ៦ឆ្នាំទាំងអស់ត្រូវ..................................

ទៅសាលារៀន ។

**ចំរៀក១៩/២០:**

ការអប់រំដែលកុមារទទួលបានត្រូវ....................................................

សមស្របទៅនឹងបរិស្ថានដែលគេរស់នៅ ។

**ចំរៀក២១/២២:**

សាលាមិនរង់ចាំកុមារ..........................................................

មកចុះឈ្មោះចូលរៀនទេតែសាលាធ្វើការស្រាវជ្រាវ ដើម្បីរកកុមារដែលគ្រប់អាយុចូលរៀន ។

**ចំរៀក២៣/២៤:**

ការបង្រៀនរបស់គ្រូទាក់ទាញអោយ.................................................... ។

សិស្សមានចិត្តចង់រៀនដោយពួកគេបានបញ្ចេញយោបល់និងធ្វើសកម្មភាពតាមក្រុមជួយគ្នាទៅវិញទៅមក ។

**ឯកសារទី៣០: សិទ្ធិកុមារ**

ថ្ងៃទី៩ ដំណាក់កាលបង្រៀនទី២

សិទ្ធិសំខាន់ៗរបស់កុមារមាន:

**១-សិទ្ធិរស់រានមានជីវិត:**

***១.១. កុមារទាំងអស់ត្រូវតែទទួលបានចំណីអាហារគ្រប់គ្រាន់ :***

-កុមារមានសិទ្ធិទទួលម្ហូបអាហារ សំលៀកបំពាក់ និងជំរកគ្រប់គ្រាន់ដើម្បីអាចរីកចំរើនធំធាត់បាន ។

*១.២ .កុមារទាំងអស់ ត្រូវតែទទួលបានការចាក់ថ្នាំបង្ការ និងថែទាំសុខភាព :*

-សុខភាពរបស់កុមារត្រូវតែទទួលបានូវការពិនិត្យ ការការពារ ការថែទាំដោយឥតគិតថ្លៃនៅពេលគេត្រូវការ ។

*១.៣ .កុមារទាំងអស់ត្រូវតែមានជំរកសមរម្យ :*

-កុមារមានសិទ្ធិទទួលម្ហូបអាហារ សំលៀកបំពាក់ និងជំរកគ្រប់គ្រាន់ដើម្បីអាចរីកចំរើនធំធាត់បាន ។

*១.៤ . កុមារទាំងងស់ត្រូវតែមានឈ្មោះ និងសញ្ជាតិ :*

-កុមារត្រូវបានចុះបញ្ជីអត្រានុគោលដ្ឋាន (បញ្ជីកំណើត) ភ្លាមក្រោយពេលប្រសូត្រចេញហើយនិងមានសិទ្ធិក្នុងការមានឈ្មោះ សិទ្ធិទទួលបានសញ្ជាតិតាំងពីពេលកើតមកភ្លាមហើយនិងមានសិទ្ធិស្គាល់ឪពុកម្តាយខ្លួនព្រមទាំងទទួលបាននូវការថែទាំពីអ្នកទាំងនោះតាមតែអាចធ្វើទៅកើត ។

**២-សិទ្ធិទទួលការការពារ :**

*២.១. ត្រូវការពារកុមារពីការរំលោភផ្លូវភេទ:*

-រាងកាយរបស់កុមារជាកម្មសិទ្ធិរបស់កុមារដែលត្រូវតែទទួលបាននូវការការពារអោយផុតពីការរំលោភផ្លូវភេទ ការបង្ខំអោយធ្វើពេស្យាកម្ម ហើយនិងអំពើអាសអាភាស ។

*២.២ .ត្រូវការពារកុមារអោយរួចផុតពីការប្រើប្រាស់គ្រឿងញៀន :*

-គ្រឿងញៀនមានគ្រោះថ្នាក់ត្រូវដាក់កុមារអោយឆ្ងាយពីគ្រឿងញៀនទាំងនោះ ។

*២.៣. ត្រូវការពារកុមារ ពីពលកម្មធ្ងន់ធ្ងរ :*

-មិនត្រូវអោយកុមារធ្វើការជាច្រើនម៉ោងឬការងារធ្ងន់ធ្ងរ ដែលអាចនាំអោយគ្រោះថ្នាក់ដល់សុខភាព និងការរីកចំរើនរបស់កុមារពីការរៀនសូត្រឡើយ ។

*២.៤. ត្រូវការពារកុមារពីអំពើហឹង្សា :*

-នេះគឺជាសិទ្ធិកុមារក្នុងការការពារ ទប់ស្កាត់កុំអោយមានការវាយដំ ការមិនអើពើថែទាំ ការធ្វើបាប និងការរំលោភមកលើកុមារ ។

**៣.សិទ្ធិក្នុងការអភិវឌ្ឍន៏ :**

*៣.១. កុមារទាំងអស់ ត្រូវតែទទួលបាននូវការអប់រំរៀនសូត្រ*

-កុមារមានសិទ្ធិទៅសាលារៀន និងសិក្សារៀនសូត្រដល់កំរិតខ្ពស់បំផុតដែលកុមារអាចធ្វើបាន។

*៣.២. កុមាត្រូវមានឱកាស ចូលរួមក្នុងសិល្បៈ វប្បធម៌ជាតិ :*

-កុមារមានសិទ្ធិលេង និងចូលរួមក្នុងផ្នែកតន្ត្រី ចំរៀង របាំ ល្ខោន សិល្បៈ ការច្នៃប្រឌិត និងសកម្មភាពវប្បធម៌ផ្សេងៗ ។

*៣.៣. កុមារត្រូវការ ការកំសាន្ត និងលំហែ :*

-កុមារមានសិទ្ធិលេង និងចូលរួមក្នុងផ្នែកតន្ត្រី ចំរៀង របាំ ល្ខោន សិល្បៈ ការច្នៃប្រឌិត និងសកម្មភាពវប្បធម៌ផ្សេងៗ ។

*៣.៤. កុមារត្រូវការ ការថែទាំយ៉ាងកក់ក្តៅ ពីក្រុមគ្រួសារ :*

-គ្រួសារមានកាតព្វកិច្ច គាំពារថែរក្សាកុមារ ។ មិនត្រូវបំបែកកុមារពីគ្រួសារដោយប្រឆាំងនឹងឆន្ទៈរបស់គេឡើយ ។

**៤.សិទ្ធិក្នុងការចូលរួម :**

*៤.១.ត្រូវអនុញ្ញាត អោយកុមារ បញ្ចេញមតិយោបល់ :*

-កុមារមានសិទ្ធិបញ្ចេញមតិយោបល់ចំពោះរាល់បញ្ហាដែលប៉ះពាល់ដល់គេ ហើយមតិយោបល់នោះត្រូវបានគេយកចិត្តទុកដាក់ស្តាប់និងពិចារណា ។

*៤.២. កុមារត្រូវចូលរួម និង បង្កើត សមាគម :*

-កុមារមានសិទ្ធិសេរីភាពចូលរួមជាមួយសហគមន៍ និងសេរីភាពធ្វើការជួបជុំដោយសន្តិវិធី។

*៤.៣.កុមារត្រូវដឹង ពីសិទ្ធិរបស់ខ្លួន :*

-សូមផ្តល់ព័ត៌មានដល់កុមារ ឪពុកម្តាយ និងមនុស្សចាស់ដទៃទៀតឱ្យយល់ដឹងអំពីសិទ្ធិកុមារនិងសិទ្ធិអនុសញ្ញាអង្គការសហប្រជាជាតិ ។

*៤.៤. កុមាត្រូវទទួលបាន និងផ្សព្វផ្សាយនូវព័ត៌មានសមស្រប :*

-កុមារមានសិទ្ធិទទួល និងផ្សព្វផ្សាយព័ត៌មាននិងបញ្ចេញមតិយោបល់របស់ខ្លួនដែលមិនប៉ះពាល់ដល់អ្នកដទៃ ។

អេស្កាប់ វគ្គបណ្តុះបណ្តាលគ្រូសហគមន៍-ឯកសាររបស់សិក្ខាកាម

**ឯកសារទី៣១: គ្រូបង្រៀនគឺជាគំរូ**

ថ្ងៃទី៩ ដំណាក់កាលបង្រៀនទី៣

ចូរជ្រើសរើសប្រយោគនៅក្នុងតារាងទី១ដែលមានប្រយោគវិជ្ជមាន និងអវិជ្ជមានទៅផ្គូរផ្គងឥរិយាបថល្អៗនៅក្នុងតារាងទី២...

| *ប្រយោគវិជ្ជមាន* | *ប្រយោគអវិជ្ជមាន* |
|---|---|
| *គ្រូជានិច្ចកាលអោយសិស្សរួមគ្នាធ្វើកិច្ចការ* | *គ្រូតែងតែហៅសិស្សដដែលៗអោយធ្វើកិច្ចការដែលមិនល្អ* |
| *គ្រូជានិច្ចកាលមកបង្រៀនទៀងទាត់ពេលវេលា* | *គ្រូចោលក្រដាសឬថង់ប្លាស្ទិចនៅលើដី* |
| *គ្រូសរសេរយ៉ាងច្បាស់ និងស្អាតនៅលើក្តារខៀន* | *ជួនកាលគ្រូមកធ្វើការយឺតពេលវេលា* |
| *គ្រូជានិច្ចកាលប្រើប្រាស់ធុងសម្រាម* | *គ្រូដើរទៅខាងក្រៅនៅពេលសិស្សធ្វើកិច្ចការឬតេស្ត* |
| *គ្រូជានិច្ចកាលនៅជាមួយសិស្សគ្រប់ពេលធ្វើការ* | *គ្រូមិនដែលដាក់កិច្ចការអោយសិស្សធ្វើនៅផ្ទះ* |
| *គ្រូមិនដែលវាយដំកុមារ* | *គ្រូប្រើប្រាស់ភាសាមិនសមរម្យ និងសំលេងតិច* |
| *គ្រូមិនដែលជក់បារីនៅក្នុងថ្នាក់រៀន* | *គ្រូសរសេរនៅលើក្តារខៀនដោយមិនយកចិត្តទុកដាក់* |
| *គ្រូនិយាយពាក្យអរគុណចំពោះកុមារ ទោះបីចំលើយនោះខុសក៏ដោយ* | *គ្រូជក់បារីនៅក្បែរឬនៅក្នុងថ្នាក់* |
| *គ្រូរួសរាយរាក់ទាក់ និងសុភាពរាបសារ* | *គ្រូប្រើរំពាត់ឬដៃវាយកុមារ* |
| *គ្រូដាក់កិច្ចការអោយសិស្សធ្វើនៅផ្ទះ* | *គ្រូរិះគន់ឬចំអកចំពោះកុមារដែលឆ្លើយខុស* |

| ឥរិយាបថល្អ | គ្រូជាគំរូ<br>វិជ្ជមាន | គ្រូជាគំរូ<br>អវិជ្ជមាន |
|---|---|---|
| យកចិត្តទុកដាក់ធ្វើការបានល្អ | | |
| ទៀងទាត់ពេលវេលា | | |
| សុភាពរាបសារ និងសំដែងការគោរពចំពោះអ្នកដទៃ | | |

| | | |
|---|---|---|
| គ្រប់គ្នាត្រូវចេះជួយថែរក្សាបរិស្ថានអោយបានល្អស្អាត | | |
| សុខភាពល្អគឺមានន័យថាមិនជក់ បារី | | |
| មិនប្រើហិង្សាដើម្បីដោះស្រាយ បញ្ហា | | |
| កុមារអាចរៀននៅក្នុង និងក្រៅសាលារៀន | | |
| ប្រព្រឹត្តដោយយុត្តិធម៌ទៅលើសិស្សគ្រប់គ្នា | | |
| ទទួលស្គាល់ការខំប្រឹងប្រែង, ទោះបីជាមានកំហុស, ធ្វើអោយអ្នកផ្សេងៗមាន អារម្មណ៍ | | |
| បង្ហាញការទទួលខុសត្រូវលើអាជីពរបស់ខ្លួន | | |

**ឯកសារទី៣២: ការធ្វើអាទិភាពសកម្មភាពរៀនដោយយោងទៅតាមការចូលចិត្ត/មិនចូលចិត្ត**

ថ្ងៃទី៩ ដំណាក់កាលបង្រៀនទី៤

នៅក្នុងតារាងខាងក្រោមបង្ហាញពីសកម្មភាពរៀនផ្សេងៗគ្នា១០ប្រភេទ និងការរៀបចំការធ្វើការងារក្នុងថ្នាក់រៀនផ្សេងៗ១០ប្រភេទទៀត។

ចូរអានរួចហើយសរសេរលេខ១ទៅ១០ នៅក្នុងតារាងនៃបញ្ជីនីមួយៗ-សរសេរលេខ១សម្រាប់អ្វីដែលអ្នកចូលចិត្តជាងគេបំផុត និងលេខ១០សម្រាប់អ្វីដែលអ្នកមិនចូលចិត្តបំផុត។ នៅទីនេះពុំមានចំលើយណាត្រឹមត្រូវនោះទេ ការងារនេះគឺចង់អោយអ្នកបញ្ចេញជាគំនិតផ្ទាល់ខ្លួនប៉ុណ្ណោះ។

**១. ប្រភេទផ្សេងៗនៃសកម្មភាពរៀន**

| សកម្មភាពរៀន | ការធ្វើចំណាត់ថ្នាក់សកម្មភាព |
|---|---|
| ការចំលងពីក្តារខៀនឬសៀវភៅ | |
| ការធ្វើលំហាត់ពីសៀវភៅដោយខ្លួនឯង | |
| ការស្តាប់គ្រូហើយធ្វើការកត់ត្រា | |
| ការចូលរួមពិភាក្សាក្រុមតូច | |
| ការធ្វើកិច្ចការស្រាវជ្រាវដោយខ្លួនឯង | |
| ការធ្វើការស្រាវជ្រាវដែលជាផ្នែកមួយនៃក្រុមតូច | |
| ការលេងល្បែងសិក្សា | |
| ការមើលរូបថតឬវីឌីអូ រួចហើយពិភាក្សា | |
| ការឆ្លើយសំនួររបស់គ្រូនៅក្នុងថ្នាក់ទាំងមូល | |
| ការឆ្លើយសំនួររបស់សិស្សផ្សេងៗនៅក្នុងក្រុមតូច | |

**២. ប្រភេទផ្សេងៗគ្នានៃការរៀបចំការធ្វើការងាររបស់សិស្ស**

| របៀបរៀបចំការងារ | ការធ្វើចំណាត់ថ្នាក់សកម្មភាព |
|---|---|
| ការធ្វើការងារដោយខ្លួនឯង | |
| ការធ្វើការងារជាមួយដៃគូ (មិត្តភ័ក្រ) | |
| ការធ្វើការងារជាមួយដៃគូ (ជ្រើសរើសដោយគ្រូ) | |

| | |
|---|---|
| ការធ្វើការជាក្រុមតូច (តិចជាង៨នាក់) | |
| ការធ្វើការងារជាក្រុមធំ (ច្រើនជាង៨នាក់) | |
| ការធ្វើការតែម្នាក់ឯង ប៉ុន្តែជាផ្នែកមួយនៃថ្នាក់ទាំងមូល | |
| ការប្រកួតប្រជែងនៅក្នុងក្រុមតូចជាមួយក្រុមដទៃ | |
| ការធ្វើតេស្តឬការប្រលងដោយខ្លួនឯង | |
| ការឡើងបង្ហាញទៅកាន់ក្រុមនៅក្នុងថ្នាក់ដោយខ្លួនឯង | |
| ការឡើងបង្ហាញ ដែលជាផ្នែកមួយនៃក្រុម | |

**ឯកសារទី៣៣: ការអាន" ការដោះស្រាយចំលើយខុស"** (ដកស្រង់ពីកញ្ចប់ TGL សំរាប់គ្រូបង្រៀនទំព័រ១៥-១៧)

ថ្ងៃទី៩ ដំណាក់កាលបង្រៀនទី៥

**ការដោះស្រាយជាមួយចំលើយខុស**

- តើអ្នកធ្វើដូចម្តេច កាលណាសិស្សឆ្លើយខុស ?
- តើការដោះស្រាយរបស់អ្នកជាមួយចំលើយខុស មានផលអ្វីខ្លះទៅលើសិស្ស?
- តើចំលើយខុសអាចមានលទ្ធផលវិជ្ជមានដែរឬទេ ?

ចូរពិនិត្យមើលបទសន្ទនាក្នុងថ្នាក់មួយនេះ :

គ្រូ : តើរដ្ឋធានីប្រទេសវៀតណាម មានឈ្មោះអ្វីដែរ បុប្ផា ?

សិស្ស : ហូជីមិញ, អ្នកគ្រូ ។

គ្រូ : ទេ មិនមែនទេ! មើល , ចិន្តា សូមឆ្លើយទៅមើល ?

សិស្ស : ហាណូយ !

គ្រូ : ចាស! ត្រូវហើយ! អ្នកគ្រូចង់អោយប្អូនទាំងអស់គ្នា.................(ការសន្ទនាបន្តទៀត)

តើសកម្មភាពបែបនេះតែងតែកើតមានរាល់ថ្ងៃក្នុងថ្នាក់រៀន ។ វាជាសកម្មភាពមួយដែលយើងគួរតែព្យាយាមចៀសវាង ដោយប្រើការឆ្លើយខុសក្នុងន័យជួយស្ថាបនាវិញ។

ចូរយើងពិនិទ្យមើលការសន្ទានេះ ។ គ្រូសួរសំណួរមួយបុប្ផាបានឆ្លើយខុស គ្រូបដិសេធចំលើយនោះ គ្រូសួរសិស្សម្នាក់ទៀតដែលឆ្លើយត្រូវ គ្រូបន្តការសួរតទៅទៀត ប៉ុន្តែមានបញ្ហា ២ :

- តើបុប្ផាមានអារម្មណ៍ដូចម្តេចដែរ ?
- តើសិស្សក្នុងថ្នាក់ដឹងថាហូជីមិញជាអ្វីដែរឬទេ ? (សិស្សមិនដឹងថាជាអ្វីទេ! )

គ្រូប្រហែលជាបានធ្វើអោយបុប្ផាមានការអន់ចិត្ត និងធ្លាក់ទឹកចិត្ត នាងប្រហែលជាមិនហ៊ានឆ្លើយទៀតទេ ។ ហើយទីពីរ គ្រូបានខកខានឱកាសមួយក្នុងការផ្តល់ព័ត៌មានបន្ថែមដល់សិស្សរបស់គាត់ គាត់មិនបានជួយអោយសិស្សបានយល់ថា តើហូជីមិញជាអ្វីទេ ?

ឥឡូវសូមពិនិត្យមើលការសន្ទនានេះ

គ្រូ : តើរដ្ឋធានីប្រទេសវៀតណាម មានឈ្មោះអ្វីដែរ បុប្ផា ?

សិស្ស : ហូជីមិញ, អ្នកគ្រូ ។

គ្រូ : អឺ... ចាស! ចុះ ចិន្តា យល់ថាម៉េចដែរ ?

សិស្ស : ហាណូយ, អ្នកគ្រូ ។

គ្រូ : អឺ, ចុះ សុវណ្ណ យល់ថាម៉េចដែរ ?

សិស្ស : ហាណូយ, អ្នកគ្រូ ។

គ្រូ : ចាស,ល្អ,ចិន្តា, ហាណូយជារដ្ឋធានីប្រទេសវៀតណាម,ប៉ុន្តែ ចុះបើតាមគំនិតរបស់បុប្ផាវិញយ៉ាងម៉េចដែរ ? បុប្ផា,អ្នកឯងឆ្លើយត្រូវដែរ, ហូជីមិញពិតជានៅក្នុងប្រទេសវៀតណាមដែរ ។ តើប្អូនណាអាចប្រាប់គ្នាយើងថែមទៀតបានទេ អំពីហូជីមិញ ? សុផល ?

សិស្ស : វាជាទីក្រុងធំទី ២ , វាស្ថិតនៅភាគខាងត្បូង, ជិតប្រទេសកម្ពុជា ។

គ្រូ : ត្រូវហើយ, ហើយបុប្ផា, ប្អូនឯងឆ្លើយជិតត្រូវពីព្រោះពីមុនវាជារដ្ឋធានីនៃវៀតណាមខាងត្បូង ។ កាលពីពេលនោះវាមានឈ្មោះផ្សេងៗ តើអ្នកណាដឹងទេថាឈ្មោះវាគឺជាអ្វីទេ កាលពីមុន ? ( ការសន្ទាបន្តទៀត )

តើយើងអាចឃើញការខុសគ្នាធំៗមួយចំនួន ចំពោះវិធីសាស្ត្របង្រៀន ក្នុងការសន្ទនាលើកទី ២ នេះ :

- គ្រូមិនបដិសេធចំលើយខុសរបស់បុប្ផាទេ ។
- គ្រូមិននិយាយភ្លាមៗថាចំលើយនេះខុសទេគាត់សួររកមតិរបស់សិស្សឯទៀត ។
- គ្រូទទួលយកចំលើយខុសរបស់បុប្ផាថាត្រូវមួយភាគដែរ គ្រូយល់ស្របថា ហូជីមិញស្ថិតក្នុងប្រទេសវៀតណាម, ហើយគាត់អរគុណបុប្ផា ការដែលបុប្ផាបានឆ្លើយចំលើយទាក់ទង គឺថាហូជីមិញជាអតីតរដ្ឋធានីនៃប្រទេសវៀតណាមខាងត្បូង ។

ចូរយើងសួរខ្លួនយើងម្តងទៀត :

តើបុប្ផាមានអារម្មណ៍ដូចម្តេចដែរ ក្រោយពីការសន្ទនានេះ ? តើសិស្សក្នុងថ្នាក់ ដឹងយ៉ាងដូចម្តេចដែរ អំពីហូជី មិញ ?

- បុប្ផាមិនមានអារម្មណ៍ធ្លាក់ទឹកចិត្តទេ ។
- បុប្ផាមានអារម្មណ៍ថាខ្លួនបានផ្តល់វិភាគទានដល់សិស្សក្នុងថ្នាក់ ។
- សិស្សក្នុងថ្នាក់ពេលនេះ ដឹងថាហូជីមិញនៅកន្លែងណាៗ ហើយដឹងថាពីមុនវាជារដ្ឋធានីនៃប្រទេសវៀតណាមខាងត្បូង, ពួកគេនឹងនឹកឃើញថាពីមុនវាមានឈ្មោះថាសៃហ្គុន ( ព្រៃនគរ ) ។

ដោយសារសកម្មភាពបែបនេះ បរិយាកាសថ្នាក់រៀនមានភាពប្រសើរ សិស្សដែលឆ្លើយខុសមានអារម្មណ៍សប្បាយចិត្ត ហើយមិនមានអារម្មណ៍ថាខ្លួនបរាជ័យទេគឺខ្លួនគេកាន់តែចេះដឹងថែមទៀត ។

ចូរព្យាយាមប្រើវិធីសាស្ត្របែបនេះ ចំពោះការខុសឆ្គងរបស់សិស្ស ។ ទោះជាការខុសឆ្គងមិនអាចត្រូវបានប្រើដើម្បីបង្កើនឱកាសរៀនសូត្រដូចមានក្នុងឧទាហរណ៍ស្រាប់នេះក៏ដោយ ក៏យ៉ាងហោចណាស់ សូមព្យាយាមកុំបដិសេធទាំងស្រុងទៅលើចំនុចខុស សូមព្យាយាមបង្វិលសំណួរនោះទៅសិស្សឯទៀត ( ដូចដែលអ្នកគ្រូ បានធ្វើក្នុងឧទាហរណ៍ ) ដើម្បីស្វែងរកចំលើយត្រូវ ។

## ឯកសារទី៣៤: រូបភាពនៃបន្ទប់រៀនពីរ

ថ្ងៃទី៩ ដំណាក់កាលបង្រៀនទី៦

រូបភាពទី១



រូបភាពទី២



## ឯកសារទី៣៥: កិច្ចការរដ្ឋបាលរបស់គ្រូបង្រៀន-សារពើភ័ណ្ឌ

ថ្ងៃទី៩ ដំណាក់កាលបង្រៀនទី៧

| ឯកសារ | គោលបំណង | ប្រគល់ជូន... |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |

**ឯកសារទី៣៦: ឧទាហរណ៍នៃសៀវភៅ/ឯកសារ ផ្សេងៗដែលប្រើប្រាស់នៅក្នុងកិច្ចការរដ្ឋបាលរបស់គ្រូបង្រៀន**

ថ្ងៃទី៩ ដំណាក់កាលបង្រៀនទី៧

**ឯកសារនិងការដកស្រង់ នៅក្នុងស្រោមថង់ផ្លាស្ទិច**

១. **បញ្ជីហៅឈ្មោះ** ទំហំ A3-សំណៅថតចំលងទំព័រមុខ (បង្ហាញសៀវភៅជាក់ស្តែងនៅក្នុងសិក្ខាសាលា)

២. **បញ្ជីអវត្តមាន** ទំហំ A3 - សំណៅថតចំលងទំព័រមុខ (បង្ហាញសៀវភៅជាក់ស្តែងនៅក្នុងសិក្ខាសាលា)

៣. **សៀវភៅសិក្ខាគារិក** -សិស្សម្នាក់ៗចាប់ពីថ្នាក់ទី៤ ទៅត្រូវមានសៀវភៅមួយនេះដែលគេរក្សាទុកនៅក្នុងសាលារៀន (ចែកជូនសៀវភៅជាក់ស្តែង)

៤. **សៀវភៅតាមដានការសិក្សា**-ក្នុង១ឆ្នាំសិក្សាសិស្សម្នាក់ៗត្រូវមានសៀវភៅនេះ ដែលគ្រូសរសេរព័ត៌មានការសិក្សាសំរាប់ផ្ញើទៅកាន់ឳពុកម្តាយរបស់សិស្សជារៀងរាល់ខែ។ (ចែកជូនសៀវភៅជាក់ស្តែង)

៥. **សៀវភៅវេន**-សៀវភៅនេះត្រូវបានផ្តល់ទៅអោយសិស្សផ្សេងៗគ្នា ជារៀងរាល់ថ្ងៃដើម្បីកត់ត្រាមេរៀន ចំណងជើងមេរៀន ប្រធានបទឬសិស្សធ្វើលំហាត់ដាក់ក្នុងសៀវភៅនោះ...(បង្ហាញសំណៅថតចំលងទំព័រមុខ និងឧទាហរណ៍ពីរបៀបសរសេរ)

៦. **សៀវភៅចូលមើលម៉ោងបង្រៀន**-សៀវភៅនេះសំរាប់អោយគ្រូធ្វើការកត់ត្រានៅពេលសង្កេតការបង្រៀនរបស់គ្រូផ្សេងដូចជា ការកត់ត្រាអ្វីដែលគេបានរៀន...( បង្ហាញសំណៅថតចំលងទំព័រមុខ និងឧទាហរណ៍ពីរបៀបសរសេរ)

៧. **សៀវភៅទំនាក់ទំនង**-សៀវភៅនេះគ្រូមានតែមួយទេសម្រាប់សិស្សទាំងអស់គ្នា គឺគ្រូប្រើដើម្បីសរសេរបញ្ហារបស់សិស្សទៅកាន់ឳពុកម្តាយរបស់គេដូចជា ការឈប់ដោយគ្មានមូលហេតុ។ល។ (បង្ហាញសំណៅថតចំលងទំព័រមុខ និងឧទាហរណ៍ពីរបៀបសរសេរ)

៨. **សៀវភៅប្រជុំបច្ចេកទេស**-សម្រាប់រាល់ការប្រជុំនៅថ្ងៃព្រហស្បតិ៍(សំណៅថតចំលងទំព័រមុខជាគំរូ)

៩. **តារាងផ្សេងៗ**

- វេនបោសសំអាត
- មធ្យមភាគប្រចាំខែ
- មធ្យមភាគប្រចាំឆមាស
- មធ្យមភាគប្រចាំឆ្នាំ
- តារាងកិត្តិយស ។ល
- សារពើភណ្ឌ
- បទបញ្ជាផ្ទៃក្នុង
- កាលវិភាគ
- កម្មវិធីសិក្សា

**ឯកសារទី ៣៦ B: បញ្ជីពិន្ទុសិស្ស**

ថ្ងៃទី៩ ដំណាក់កាលបង្រៀនទី៧ សាលាបឋមសិក្សា..............................ថ្នាក់ទី.................ខែ................ឆ្នាំ..............

| ប្រុស | ស្រី | សរុប |
|---|---|---|
| | | |

| លរ | នាម និង គោត្តនាម | ភាសាខ្មែរ | | | | | | គណិតវិទ្យា | | | | សិក្សាសង្គម | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | សំនេរ | | | | | | | វិជ្ជាសង្គម | | | អប់រំសិល្បៈ | | | | | | | | | |
| | | ស្តាប់ | និយាយ | អំណាន | សរសេរតាមអាន | តែងសេចក្តី | វេយ្យាករណ៍ | កិច្ចការផ្ទាល់មាត់ | សំនេរក្នុងថ្នាក់ | កិច្ចការនៅផ្ទះ | វិទ្យាសាស្ត្រអនុវត្ត | ភូមិវិទ្យា | ប្រវត្តិវិទ្យា | អប់រំពលរដ្ឋ | អក្សរផ្ចង់ | គំនូរ | ចំរៀង-របាំ | បច្ចេក | ភាសាបរទេស | កីឡា | ពិន្ទុសរុប | មធ្យមភាគ | ចំណាត់ថ្នាក់ | សេចក្តីផ្សេងៗ |
| ១ | ចិន ទូទូ | ៨ | ៧ | ៩ | ១០ | | | ៩ | ១០ | ៩ | ៧ | ៩ | | ១០ | ៧ | | | | | | | | | |
| ២ | ជាម រម្យនា | ៦ | ៧ | ៦ | ១០ | | | ៧ | ១០ | ៦ | ៨ | ៧ | | ៩ | ៥ | | | | | | | | | |
| ៣ | ឈឿន គន្ធា | ៥ | ៦ | ៥ | ៧ | | | ៧ | ៣ | ៦ | ៥ | ៦ | | ៤ | ៥ | | | | | | | | | |
| ៤ | ញឹម សុខលី | ៥ | ៧ | ៦ | ៥ | | | ៧ | ៦ | ៦ | ៦ | ៧ | | ៩ | ៥ | | | | | | | | | |
| ៥ | ញៀន ភារម្យ | ៨ | ៧ | ៧ | ១០ | | | ៩ | ៨ | ៨ | ៤ | ៩ | | ៩ | ៦ | | | | | | | | | |
| ៦ | ណុប ចាន់នឿន | ៨ | ៥ | ៧ | ៦ | | | ៦ | ៨ | ៦ | ៧ | ៨ | | ៦ | ៦ | | | | | | | | | |
| ៧ | ថៃ រសាត | ៧ | ៦ | ២ | ៨ | | | ៥ | ២ | ៥ | ៣ | ៦ | | ២ | ៥ | | | | | | | | | |
| ៨ | ទី ចាន់ធឿន | ៦ | ៦ | ៤ | ៥ | | | ៥ | ៥ | ៦ | ៣ | ៧ | | ៤ | ៤ | | | | | | | | | |
| ៩ | ប៊ូ ចំរុង | ៩ | ៧ | ៣ | ៩ | | | ៩ | ១០ | ៩ | ៧ | ៧ | | ៧ | ៧ | | | | | | | | | |
| ១០ | ប៉ា ស៊ីម៉ូ | ៨ | ៦ | ៥ | ៩ | | | ៦ | ៦ | ៦ | ៣ | ៨ | | ៤ | ៤ | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |

បានឃើញ និង ឯកភាព ធ្វើនៅ.................ថ្ងៃទី....ខែ.......ឆ្នាំ..........

នាយកសាលា គ្រូប្រចាំថ្នាក់

សរុបសិស្សបានមធ្យមភាគ
- ៥ - ៦,៤៩ មាន...........................នាក់
- ៦,៥០ - ៧,៩៩...........................នាក់
- ៨,០០ - ៩,៤៩.............................នាក់
- ៩,៥០ - ១០,០០...........................នាក់
- ចំនួនសិស្សក្រោមមធ្យមភាគៈ..........នាក់

**ឯកសារទី៣៧: ការទទួលខុសត្រូវលើកិច្ចការគ្រប់គ្រងថ្នាក់រៀន**

ថ្ងៃទី៩ ដំណាក់កាលបង្រៀនទី៨

| ការងារក្នុងថ្នាក់រៀន | ការទទួលខុសត្រូវរបស់... | | |
|---|---|---|---|
| | គ្រូ | សិស្ស | ទាំងពីរ |
| ចុះបញ្ជី | | | |
| ចែក/ប្រមូលសៀវភៅ និងក្រដាសផ្សេងៗ | | | |
| កំណត់ពេលចេញលេង/សំរាក | | | |
| ជ្រើសរើសសម្ភារ | | | |
| ផ្តល់ការសរសើរ | | | |
| សំអាតបន្ទប់រៀន | | | |
| សរសេរលើក្តារខៀន | | | |
| ប្រើសម្ភារឧបទេស | | | |
| រៀបចំសម្ភារឧបទេស | | | |
| បំលាស់ទីគ្រឿងសង្ហារឹម | | | |
| រក្សាវិន័យ | | | |
| កំនត់/បែងចែកវេនដែលត្រូវនិយាយ | | | |
| រៀបចំផែនការមេរៀន | | | |
| បង្កើតក្រុម | | | |
| រក្សាក្តារបិទប្រកាស | | | |
| កែកិច្ចការផ្ទះ | | | |
| ផ្តល់មតិកែលំអ | | | |

**ឯកសារទី៣៨៖ អ្នកពាក់ព័ន្ធក្នុងការអប់រំ**

ថ្ងៃទី១០ ដំណាក់កាលបង្រៀនទី២

| អ្នកពាក់ព័ន្ធ | តើមូលហេតុអ្វីបានជាអ្នកពាក់ព័ន្ធមានចំណាប់អារម្មណ៍ក្នុងការធ្វើផែនការអភិវឌ្ឍសាលារៀន? |
|---|---|
| ឪពុកម្តាយសិស្ស | |
| គ្រូបង្រៀន | |
| នាយកសាលារៀន | |
| សហគមន៍ | |
| គណៈកម្មការទ្រទ្រង់សាលារៀន | |
| កុមារ | |
| ក្រសួងអប់រំ | |
| អាជ្ញាធរមូលដ្ឋាន | |
| វត្តអារ៉ាម ព្រះសង្ឃ | |
| | |

**ឯកសារទី៣៩: គោលការណ៍នៃអភិបាលកិច្ចល្អ**

ថ្ងៃទី១០ ដំណាក់កាលបង្រៀនទី៣

ក្នុងការទំនាក់ទំនងសាលារៀន និងសហគមន៍ត្រូវគោរពគោលការណ៍អភិបាលកិច្ចល្អដែលមាន តំលាភាព ទំនួលខុសត្រូវ ប្រសិទ្ធភាព និង ការចូលរួម ។

## 1. តំលាភាព

រដ្ឋបាលសាធារណៈត្រូវមាន តំលាភាពដើម្បីធ្វើអោយគោលការណ៍និតិរដ្ឋត្រូវបានគោរព និងអនុវត្តគ្រប់ៗគ្នា ។ តំលាភាពនេះមានន័យថាជាការចាត់ទុកបុគ្គលគ្រប់រូបស្មើភាពគ្នាទាំងអស់នៅចំពោះមុខច្បាប់ និងកាតព្វកិច្ច នៅក្នុងក្របខ័ណ្ឌគតិយុត្តិ និង បទបញ្ញត្តិមួយជាក់លាក់ ។

តំលាភាពស្តែងឡើងតាមរយៈ ការស្មោះត្រង់ យុត្តិធមិ សមធមិ មនុស្សធមិ ដែលមាន ÷

⋆ **ការស្មោះត្រង់** ដោយបណ្តុះស្មារតីសុចរិតគឺភាពជាក់ស្តែងច្បាស់លាស់ គ្មានគំនិតលាក់លៀម ( កំហុសពិសោធ ចំណេះដឹង..) គ្មានពុតត្បុតវៀរចាកការនិយាយមិនពិត(កុហក មួលបង្កាច់ បំផ្លើស)មិនបោកប្រាស់អ្នកដទៃ(គ្រួសារ មិត្តភក្តិ អ្នករួមការងារ) មិនអោយគេមានការមន្ទិលសង្ស័យមិនត្រូវមានចិត្តលោភលន់ (ទ្រព្យសម្បត្តិ អ្នកដទៃ ឯកជន ទ្រព្យសម្បត្តិសាធារណៈ ) មិនកេងប្រវ័ញ្ច ( ពលកម្ម ទ្រព្យឯកជន សាធារណៈ ) មិនត្រូវប្រកាន់ចិត្តច្រណែនឈ្នានីស អ្នកដទៃ ( ដោយ ឃើញគេល្អជាង ខ្ពស់ជាង មានទ្រព្យជាង ពូកែជាង ) មិនត្រូវប្រកាន់បក្សពួក ( សាច់ញាតិ មិត្តភក្តិ បងប្អូន....) ។

ដើម្បីធានាយុត្តិធមិនិងសមធមិសង្គមសាលារៀនត្រូវតែនៅជិតនឹងប្រជាជន និងយកចិត្តទុកដាក់ដល់ជីវភាពរបស់ប្រជាជន ។ នេះមានន័យថាសាលារៀនត្រូវមានវត្តមាននៅទីណាដែលមានតំរូវការរបស់ប្រជាពលរដ្ឋ ។

⋆ **ស្មារតីស្រឡាញ់យុត្តិធមិ មនុស្សធមិ** គឺ ស្មារតីសមភាព ភាតរភាព សាមគ្គីភាព គោរពអនុវត្ត និង ការពារ វិន័យ បទដ្ឋានច្បាប់សិទ្ធិមនុស្ស (កុមារ និង ស្ត្រី ) យកចិត្តទុកដាក់ចំពោះអ្នកដទៃក៏ដូចជាចំពោះខ្លួនផ្ទាល់ (សុខភាព ផលប្រយោជន៍ ) ដោះស្រាយបញ្ហាដោយអហឹង្សាមិនរើសអើងជាតិសាសន៍ ពូជពង្ស ភេទ វណ្ណៈ សាសនា......។

ការងារទំនាក់ទំនងសាលារៀន និងសហគមន៍ត្រូវការជាចាំបាច់នូវតំលាភាពដែលប្រកបដោយការស្មោះត្រង់ យុត្តិធមិ សច្ចធមិ មនុស្សធមិទើបការងារនេះសំរេចជោគជ័យ ។

## 2. ទំនួលខុសត្រូវ

នាយកសាលាត្រូវតែមានសមត្ថភាព និងការទទួលខុសត្រូវ ។ ទំនួលខុសត្រូវស្តែងឡើងតាមរយៈ ទំនួលខុសត្រូវចំពោះខ្លួនឯងគ្រួសារ សាលារៀន និងសហគមន៍ ÷

⋆ **ទំនួលខុសត្រូវចំពោះខ្លួនឯង** គឺការហ៊ានទទួលខុសត្រូវលើអំពើរបស់ខ្លួនដែលបានប្រព្រឹត្តរួចហើយទទួលស្គាល់កំហុសខ្លួនឯងជាមុនទើបយើងអាចដឹងកំហុសអ្នកដទៃ ហ៊ានទទួលខុសត្រូវលើអំពើដែលខ្លួនប្រព្រឹត្តដោយអចេតនាក្តី

ក្លាហាន ក្នុងការទទួលកំហុសនិងកែប្រែមករកផ្លូវត្រូវឬល្អវិញ ថ្លឹងថ្លែងចំនុចខ្លាំង ខ្សោយរបស់ខ្លួន បណ្តុះការទុកចិត្តលើខ្លួនឯង បណ្តុះការជឿជាក់លើខ្លួនឯង......។

⋆ **ទំនួលខុសត្រូវចំពោះគ្រួសារ** គឺការហ៊ានទទួលខុសត្រូវលើអំពើរបស់ខ្លួនចំពោះមុខសមាជិកគ្រួសារ ការហ៊ានទទួលកំហុសដោយមិនលាក់លៀម និងលាតត្រដាងការពិត ស្គាល់ស្ថានភាព និងតួនាទីរបស់ខ្លួនក្នុងគ្រួសារ ថែរក្សាការពារកិត្តិយសគ្រួសារ ក្លាហានក្នុងការទទួល និងកែប្រែកំហុសឡើងវិញ.......។

⋆ **ទំនួលខុសត្រូវចំពោះសាលារៀន** គឺការហ៊ានទទួលខុសត្រូវលើសកម្មភាពការងាររបស់ខ្លួន ស្គាល់ចំណុចខ្លាំង /ខ្សោយរបស់ខ្លួនហ៊ានទទួលស្គាល់កំហុសរបស់ខ្លួនចំពោះមិត្តរួមការងារ ហ៊ានទទួលខុសត្រូវក្នុងកាតព្វកិច្ច ហ៊ានទទួលខុសត្រូវក្នុងការបញ្ចេញមតិយោបល់ ទទួលខុសត្រូវក្នុងសីលធម៌រស់នៅល្អ បំពេញការងារល្អ.......។

⋆ **ទំនួលខុសត្រូវចំពោះសហគមន៍** គឺការបើកឱកាសអោយអ្នកដទៃសាកសួរ និងបញ្ចេញយោបល់ ហ៊ានទទួលខុសត្រូវក្នុងការសំរេចចិត្ត ការប្តេជ្ញាចិត្តធ្វើអោយបានសំរេច ហ៊ានទទួលខុសត្រូវក្នុងមុខនាទីរបស់ខ្លួន ហ៊ានទទួលខុសត្រូវចំពោះពាក្យសំដី និងកិច្ចសន្យា គោរពភារកិច្ច គោរពច្បាប់និងបទបញ្ជា / សីលធម៌សង្គមទៅតាមពេលវេលានិងទីកន្លែងស្គាល់ព្រំដែននៃការប្រព្រឹត្តរបស់ខ្លួន គោរពសមូហភាពបុគ្គលទទួលខុសត្រូវ ទទួលស្គាល់ភាពចាំបាច់និងតំរូវការអ្នកដទៃ មានមនសិការការងារ ទទួលខុសត្រូវក្នុងការការពារសម្បត្តិវប្បធម៌ ទទួលខុសត្រូវក្នុងការការពារថែរក្សាប្រពៃណីទំនៀមទម្លាប់ ទទួលខុសត្រូវក្នុងការថែរក្សាបរិស្ថានធម្មជាតិ និងសង្គម ទទួលខុសត្រូវថែរក្សាសម្បត្តិសាធារណៈ សណ្តាប់ធ្នាប់សន្តិសុខសង្គម គោរពពេលវេលាក្នុងការបំពេញភារកិច្ច ភាពម៉ឺងម៉ាត់ក្នុងការងារភ្ញាក់រលឹកលើការងារ ស្រលាញ់ការងារ ព្រមទទួលការទិតៀនពីអ្នកដទៃ.......។

នាយកសាលាដែលមានសមត្ថភាពនិងទំនួលខុសត្រូវចំពោះខ្លួនឯង គ្រួសារនិងសាលារៀនដែលខ្លួនគ្រប់គ្រង ធ្វើអោយសហគមន៍ ជឿជាក់ និង ទុកចិត្តហើយគេនឹងចូលរួមក្នុងគ្រប់ការងាររបស់សាលារៀន ។

## 3. ប្រសិទ្ធភាព

ការងារទំនាក់ទំនងសាលារៀននិងសហគមន៍មានគោលបំណងជាបឋមអោយសមាជិកក្នុងសហគមន៍និងអង្គភាពសាលារៀនរួមមានគ្រូបង្រៀន ព្រះសង្ឃ មាតាបិតា គណៈកម្មការទ្រទ្រង់សាលារៀន គណៈកម្មការអាចារ្យវត្តនិង រដ្ឋអំណាចមូលដ្ឋានយកចិត្តទុកដាក់ ចូលរួមអោយបានខ្លាំងក្លាផុលផុស និងសកម្មនៅក្នុងដំណើរការអភិវឌ្ឍសាលារៀន និងសហគមន៍ក្នុងទិសដៅរួមដើម្បីលើកកំពស់គុណភាពអប់រំរបស់សិស្សទាំងនៅក្នុងសាលារៀន និងនៅក្រៅសាលារៀន (សហគមន៍) អោយមានប្រសិទ្ធភាពដើម្បីធានាដល់ការសិក្សាដោយកាត់បន្ថយអត្រាត្រួតថ្នាក់បោះបង់ការសិក្សា និងជួយដល់សិស្សដែលមិនបានចូលរៀនឬកុមារដែលបានបោះបង់ការសិក្សាបានចូលរៀន និងធ្វើយ៉ាងណាអោយសិស្សទាំងអស់នោះទទួលបានពេញលេញនូវចំណេះដឹងបំណិនប្រសប់ និងបុគ្គលិកលក្ខណៈពីការសិក្សារបស់ពួកគេ ។

⋆ **ទំនាក់ទំនងត្រូវមានគំនិត និងគោលបំណងច្បាស់លាស់ដើម្បីទំនាក់ទំនងគ្នា:** ក្នុងការធ្វើទំនាក់ទំនងនឹងភ្នាភាគីម្ខាងៗត្រូវគិតជាមុនសិនថា តើត្រូវនិយាយយ៉ាងណា ? និយាយអ្វីខ្លះ ? កុំអោយនិយាយបែកពពុះមាត់រកកន្លែងចប់មិនឃើញ ។ កុំអោយគេនិយាយថានិយាយមួយសន្ទុះធំហើយ តែមិនដឹងចង់និយាយពីរឿងអ្វី ។

ហេតុនេះគប្បីគិតគូររកគំនិត និងគោលបំណងអោយបានត្រឹមត្រូវច្បាស់លាស់ជាមុនសិនមុននឹងនិយាយដើម្បីឱ្យការធ្វើទំនាក់ទំនងបានឈានទៅដល់គោលបំណងដែលយើងចង់បាន និងប្រកបដោយភាពស្និទ្ធស្នាល និងរីករាយ ។

⋆ **ទំនាក់ទំនងត្រូវមើលបរិយាកាស និង ពេលវេលា:** ការធ្វើទំនាក់ទំនងជាមួយសហគមន៍ សាលារៀនត្រូវមើលបរិយាកាស តើកន្លែងជួបគ្នាប្រជុំតូចឬធំ ភ្លឺឬងងឹត ក្ដៅឬទេ ហើយនៅជុំវិញខាងក្រៅមានសម្លេងរំខានឬទេ ។ បើសិនជាកន្លែងប្រជុំឬធ្វើទំនាក់ទំនងមានសភាពតូចចង្អៀត ងងឹត ក្ដៅហើយមានសម្លេងរំខានស្ដាប់មិនបាននោះ ការប្រជុំឬការធ្វើទំនាក់ទំនងនោះច្បាស់ជាពុំបានលទ្ធផលល្អឡើយ ។ ការទំនាក់ទំនងជាមួយសហគមន៍ សាលារៀនក៏ត្រូវតែគិតគូរពីពេលវេលាជាចាំបាច់ ព្រោះប្រជាជនក្នុងសហគមន៍គាត់មានការងារមុខរបរចិញ្ចឹមជីវិតជារៀងរាល់ថ្ងៃ។ ការប្រជុំបើធ្វើចំពេលគាត់រវល់ឬជួនកាលប្រជុំយូរពេកនោះលទ្ធផលច្បាស់ជាពុំបានលទ្ធផលល្អឡើយ ។ ហេតុនេះទំនាក់ទំនងសាលារៀននិងសហគមន៍ចាំបាច់ណាស់ត្រូវជ្រើសរើសទីកន្លែងសមរម្យ កំណត់ពេល និងជ្រើសរើសពេលឱ្យបានសមស្រប ។

## 4. <u>**ការចូលរួម**</u> :

ក្នុងសាលារៀនគ្រូជាអ្នកអប់រំមានបច្ចេកទេស និងក៏រិតវប្បធម៌ខ្ពង់ខ្ពស់ ។ ក៏ប៉ុន្តែគ្រូបង្រៀនមិនត្រូវគិតថាខ្លួនពុំមានការខ្វះខាតឬគិតថាខ្លួនពូកែទាំងអស់នោះទេ ។ មានចំណុចជាច្រើនណាស់ដែលមនុស្សចេះមិនអស់។

ប្រជាជនក្នុងសហគមន៍អាចមានជំនាញខាងផ្នែកអ្វីមួយដែលគ្រូយើងគ្មាន ហេតុនេះសាលារៀនគួរទំនាក់ទំនងអញ្ជើញគាត់មកជួយពន្យល់ឬបង្រៀនដល់គ្រូ និងសិស្ស ។

ចំណែកសាលារៀនវិញតែងតែទទួលបាននូវបច្ចេកទេសថ្មី បទពិសោធន៍ថ្មី វិទ្យាសាស្ត្រជឿនលឿន ។ ហេតុនេះ បើមានផ្នែកណាមួយដែលមានប្រយោជន៍ដល់ប្រជាជនក្នុងសហគមន៍ សាលារៀនត្រូវតែទំនាក់ទំនងផ្សព្វផ្សាយអោយគាត់បានដឹងបានយល់ឬបានឃើញផង ។

ការអប់រំកុមារ និងយុវជនសាលារៀនត្រូវតែមានការចូលរួមពីសហគមន៍ជាចាំបាច់ណាស់។ សាលារៀនម្នាក់ឯងមិនអាចដំណើរការអប់រំបានលទ្ធផលល្អឡើយ ។

សហគមន៍ជាដៃគូយ៉ាងសំខាន់ និងខានមិនបានរបស់សាលារៀនក្នុងការអប់រំកុមារ និងយុវជនអោយគេក្លាយទៅជាកុមារល្អមានគុណធម៌ ចរិយាធម៌ និងមានចំណេះវិជ្ជាគ្រប់គ្រាន់អាចបន្តការសិក្សា ហើយទីបញ្ចប់គេនឹងក្លាយទៅជាមនុស្សពេញលេញ ជាពលរដ្ឋល្អបាន ។

ប្រជាជនខ្មែរយើងមានប្រពៃណី ទំនៀមទម្លាប់ដ៏ល្អជាអ្នកកាន់ព្រះពុទ្ធសាសនាចេះគោរពគ្នា ជួយយកអាសារគ្នា សាមគ្គីយោគយល់គ្នាដ៏ប្រពៃហើយទន្ទឹមនឹងនេះប្រជាជនយើងមានបទពិសោធដ៏សំបូរបែបលើការងារគ្រប់គ្រង ការងារបច្ចេកទេសផ្សេងៗ ការងារកសិកម្ម ជំនួញដូរ ។ល។ តើយើងត្រូវទាញយកបទពិសោធល្អៗរបស់សហគមន៍មកប្រើប្រាស់ក្នុងសកម្មភាពបង្រៀន និងរៀនក្នុងសាលារៀនបានយ៉ាងណាដែរ? ដោយយើងមើលឃើញថាសហគមន៍ជាជង្រុកនៃចំណេះដឹង និងបទពិសោធដ៏សំបូរបែប ដូចនេះសាលារៀន គ្រូបង្រៀនរបស់យើងអាចមានលទ្ធភាព ទាញយកវាមកប្រើប្រាស់ក្នុងសាលារៀនដើម្បីពង្រឹងគុណភាពនៃការសិក្សារបស់សិស្ស ។

**ឯកសារទី៤០: គណៈកម្មការទ្រទ្រង់សាលារៀន និងកម្មវិធីសកម្មភាពជាអាទិភាព**

ថ្ងៃទី១០ ដំណាក់កាលបង្រៀនទី៤

**១. សមាសភាពគណៈកម្មការ :**

គណៈកម្មការនេះបង្កើតឡើងដោយកាបោះឆ្នោតជ្រើសរើសក្នុងជួរមាតាបិតាសិស្សដែលសកម្ម និងមានប្រជាប្រិយភាព ។ សមាសភាពគណៈកម្មការទ្រទ្រង់សាលាមានពី៥រូបទៅ៩រូប តាមស្ថានភាពជាក់ស្តែងរបស់មូលដ្ឋាន :

- ប្រធានកិត្តិយស : ជ្រើសរើសក្នុងចំណោមព្រះគ្រូចៅអធិការវត្តឬអាជ្ញាធរដែនដី ។
- ប្រធាន : ជ្រើសរើសឡើងក្នុងចំណោមអ្នកមានឥទ្ធិពលមាតាបិតាសិស្សអ្នកមុខអ្នកការ ។
- អនុប្រធាន : ជ្រើសរើសឡើងអ្នកដឹកនាំសាលារៀន ( នាយក ឬ នាយករង ) ។
- ហិរញ្ញិក : ជ្រើសរើសឡើងក្នុងចំណោមលោកគ្រូ អ្នកគ្រូឬមាតាបិតាសិស្សដែលមានចំណេះដឹង បទពិសោធន៍ និងស្មោះត្រង់ ។
- លេខាធិការ : ជ្រើសរើសឡើងក្នុងចំណោមនាយករងឬគ្រូបង្រៀន ។
- សមាជិក : ជ្រើសរើសឡើងក្នុងចំណោមតំណាងមាតាបិតាសិស្ស ( អាចពី១ទៅ៥នាក់ ) គណៈកម្មការទ្រទ្រង់សាលាត្រូវបានទទួលស្គាល់ជាផ្លូវការដោយអាជ្ញាធរដែនដីតាមឋានានុក្រមត្រឹមថ្នាក់ស្រុកដែលមានអាណត្តិ ១ ឆ្នាំសិក្សា ។

**២. ភារកិច្ច :**

- ស្វែងរកការជួយឧបត្ថម្ភគាំទ្រជាសំភារៈ និងថវិកាសំរាប់ទ្រទ្រង់សាលារៀន ។
- បំផុសចលនាសាងសង់ និងជួសជុលសាលារៀននៅក្នុងសហគមន៍ ។
- គ្រប់គ្រងថវិកាសហគមន៍ ។
- រួមចំនែកទទួលខុសត្រូវលើរាល់ការចំណាយថវិការបស់សាលារៀន ។
- ចូលរួមសាងផែនការអភិវឌ្ឍសាលារៀន ។
- ជួយពង្រឹងវិន័យ សណ្តាប់ធ្នាប់ និងសីលធម៌រស់នៅរបស់សិស្ស ។
- សហការជាមួយមាតាបិតាសិស្សដើម្បីជំរុញការសិក្សារបស់សិស្ស ។
- ពង្រីកការយល់ដឹងរបស់ប្រជាជន ក្នុងសហគមន៍ ។

បន្ថែមលើកិច្ចការខាងលើក្នុងការចូលរួមអនុវត្តកម្មវិធីសកម្មភាពជាទិភាពរបស់សាលា គណៈកម្មការទ្រទ្រង់សាលាត្រូវ :

- ផ្សព្វផ្សាយដល់សហគមន៍ មាតាបិតាសិស្ស :
  + គោលនយោបាយស្តីពីការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន តាមរយៈការមិនយកវិភាគទាន ពីសិស្ស ។
  + ខ្លឹមសារកម្មវិធីសកម្មភាពអាទិភាព ។

+ ផ្តល់តួនាទីយ៉ាងសំខាន់ដល់សហគមន៍ ក្នុងការចូលរួមអភិវឌ្ឍសាលារៀន ។

- ចូលរួមពិនិត្យការប្រើប្រាស់ថវិកា ។
- ចូលរួមជំរុញការលើកទឹកចិត្ត ដល់នាយក – គ្រូបង្រៀន ។
- ចូលរួមផ្តល់យោបល់គ្រប់សកម្មភាពក្នុងការអភិវឌ្ឍសាលារៀន ។
- រិះរកគ្រប់មធ្យោបាយលើការសាងសង់ផ្សេងៗ ដែលមិនអាចប្រើប្រាស់ថវិកាកម្មវិធីសកម្មភាពជាអាទិភាពបាន។

## ៣. របបប្រជុំ :

គណៈកម្មការទ្រទ្រង់សាលាត្រូវរៀបចំការប្រជុំយ៉ាងតិច៣ដងក្នុងមួយឆ្នាំ : នៅមុនបវេសនកាល ដំណាច់ឆមាសលើកទី ១ និង ដំណាច់ឆ្នាំ ។

១. <u>ការប្រជុំមុនបវេសនកាល</u> : មុនបើកបវេសនកាល នាយកសាលាគប្បីធ្វើលិខិតនិមន្ត និងការអញ្ជើញ ព្រះចៅអធិការវត្ត អាជ្ញាធរដែនដីស្រុក ប្រធានការិយាល័យអប់រំយុវជន និងកីឡាស្រុក មាតាបិតាសិស្សទាំងអស់ ក្នុងសហគមន៍អោយចូលរួមប្រជុំតាមកាលកំណត់ និងមានរបៀបវារៈប្រជុំ ។

- រាយការណ៍ចំនូលចំនាយនៃការជួសជុល និងសាងសង់របស់ថវិកាសហគមន៍ ។ និងរបាយការណ៍ចំណូលចំណាយថវិកាសាលារៀន ។
- ប្រមូលព័ត៌មានទិន្នន័យតំរូវការជួសជុលតូចតាចជួសជុលធំ និងសាងសង់ ។
- ផ្សព្វផ្សាយសេចក្តីណែនាំផ្សេងៗរបស់ក្រសួងអប់រំយុវជន និង កីឡា ផែនការពង្រីកអប់រំ និង ធ្វើសំនូមពរចាំបាច់របស់សាលារៀនសំរាប់ពេលខាងមុខ ។ ជ្រើសរើសសមាសភាពគណៈកម្មការទ្រទ្រង់សាលាថ្មី តាមការបោះឆ្នោតសំរាប់អាណត្តថ្មី ។
- បែងចែកភារកិច្ចដល់សមាសភាពគណៈកម្មការទ្រទ្រង់សាលា ។

២. <u>ការប្រជុំនៅដំណាច់ឆមាសទី ១</u> :

- គណៈកម្មការទ្រទ្រង់សាលាសហការជាមួយមាតាបិតាសិស្សពិនិត្យមើលការសិក្សារបស់សិស្សអត្រាបោះបង់ការសិក្សា និងវិន័យសណ្តាប់ធ្នាប់របស់សិស្ស ។
- ដាក់វិធានការជំរុញការសិក្សារបស់សិស្សអោយកាន់តែប្រសើរជាងមុន ។
- ត្រួតពិនិត្យការងារជួសជុល និងសាងសង់។
- ធ្វើរបាយការណ៍បូកសរុបនិងវាយតំលៃការងារអប់រំនៅឆមាសទី១ និងលើកផែនការអនុវត្តនៅឆមាសទី ២ ។

៣. <u>ការប្រជុំនៅដំណាច់ឆ្នាំ</u> :

- ពិនិត្យ និងផ្ទៀតផ្ទាត់ការជួសជុល និងសាងសង់ នឹងការចាយវាយថវិកាសាលា ។
- ធ្វើរបាយការណ៍បូកសរុប និងវាយតំលៃការងារអប់រំ និងលើកផែនការសំរាប់អនុវត្តឆ្នាំសិក្សាក្រោយ ។

**ឯកសារទី៤១: គណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នាថ្នាក់ឃុំ**

ថ្ងៃទី១០ ដំណាក់កាលបង្រៀនទី៦

***ការអប់រំសំរាប់ទាំងអស់គ្នាគឺជាអ្វី?***

ការអប់រំសំរាប់ទាំងអស់គ្នាគឺជាចលនារបស់ពិភពលោក ដើម្បីអោយកុមារ យុវជន និងជនពេញវ័យគ្រប់រូបមានសិទ្ធិទទួលផលប្រយោជន៍ពីការអប់រំមូលដ្ឋានបានយ៉ាងពេញលេញ និងប្រកបដោយគុណភាពខ្ពស់។

ការអប់រំគឺជាសិទ្ធិមូលដ្ឋានរបស់មនុស្សជាតិ។ ការអបរំគឺជាគន្លឹះឆ្ពោះទៅរកការអភិវឌ្ឍសន្តិភាព និងស្ថេរភាពប្រកបដោយនិរន្តរភាពនៅក្នុងផ្ទៃប្រទេស និងរវាងប្រទេសនានា។ អាស្រ័យហេតុនេះហើយការអប់រំគឺជាមធ្យោបាយដែលមិនអាចខ្វះបានដើម្បីអោយមានការចូលរួមប្រកបដោយប្រសិទ្ធភាពនៅក្នុងសង្គម និងសេដ្ឋកិច្ចនាសតវត្សទី២១ដែលទទួលឥទ្ធិពលពីដំណើរការសកលភាវូបនីយកម្មដ៏ឆាប់រហ័ស។ ការធ្វើអោយសម្រេចបាននូវគោលដៅអប់រំសំរាប់ទាំងអស់គ្នាមិនត្រូវពន្យារពេលយូរទៀតទេ។ សេចក្តីត្រូវការក្នុងការរៀនសូត្រជាមូលដ្ឋានអាចដោះស្រាយបាន និងត្រូវតែដោះស្រាយជាបន្ទាន់។

ដើម្បីឆ្លើយតបទៅនឹងចលនាអប់រំពិភពលោកនេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតយន្តការជាតិអប់រំសំរាប់ទាំងអស់គ្នាដែលមានជាលំដាប់ថ្នាក់ដូចខាងក្រោម:

- គណៈកម្មាធិការជាតិអប់រំសំរាប់ទាំងអស់គ្នា
- គណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នាថ្នាក់ខេត្ត/ក្រុង
- គណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នាថ្នាក់ស្រុក/ខណ្ឌ
- គណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នាថ្នាក់ឃុំ/សង្កាត់

គណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នាថ្នាក់ឃុំ/សង្កាត់ គឺជាគណៈកម្មាធិការមួយដែលមានសមាសភាពនៅក្នុងមូលដ្ឋាន ផ្ទាល់ហើយមានតួនាទី និងភារកិច្ចសំខាន់ណាស់នៅក្នុងការអប់រំ។

**សមាសភាពគណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នាថ្នាក់ឃុំរួមមាន:**

- មេឃុំ
- ក្រុមប្រឹក្សាឃុំដែលទទួលបន្ទុកសេវាអប់រំ
- នាយក និងនាយករងវិទ្យាល័យឬអនុវិទ្យាល័យ
- នាយកសាលាបឋមសិក្សា២នាក់ក្នុងមួយឃុំ

- ប្រធានកម្រងសាលារៀន
- គ្រូបង្គោលឃុំ
- មេភូមិ

តួនាទី និងភារកិច្ចគណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នាថ្នាក់ឃុំ

- ➢ រៀបចំផែនការអភិវឌ្ឍកម្មវិធីអប់រំសំរាប់ទាំងអស់គ្នាអោយបានសមស្របតាមគោលដៅរបស់ជាតិ ខេត្ត/ក្រុង ស្រុក/ខ័ណ្ឌ និង ស្ថានភាពជាក់ស្តែងរបស់មូលដ្ឋាន
- ➢ បំផុសស្មារតីរបស់ប្រជាពលរដ្ឋនិង អ្នកដឹកនាំនៅក្នុងមូលដ្ឋានអោយចូលរួមក្នុងកម្មវិធីអោយបានច្រើន
- ➢ កៀរគរ និង ប្រើប្រាស់ធនធានដែលមាននៅក្នុងមូលដ្ឋាន
- ➢ សម្របសម្រួលជាមួយគ្រឹះស្ថានសិក្សានានា និង ភ្នាក់ងារមូលដ្ឋានដទៃទៀត
- ➢ ធ្វើការប្រជុំតាមការចាំបាច់ ដើម្បីវាយតំលៃការងារដែលបានដាក់ចុះ
- ➢ ចុះតាមដានវាយតំលៃសកម្មភាពអប់រំសំរាប់ទាំងអស់គ្នាតាមភូមិជាប្រចាំ
- ➢ រៀបចំរបាយការណ៍ជារៀងរាល់ខែផ្ញើជូនគណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នាថ្នាក់ស្រុក/ខណ្ឌ

នៅខាងក្រោមនេះគឺជាតួនាទីមួយផ្នែកជាក់លាក់ផ្សេងទៀតដែលទាក់ទងផ្ទាល់ជាមួយគ្រូសហគមន៍ទាំងអស់គឺ:

- ➢ រៀបចំបែងចែកការងារ
- ➢ បើកសម្ភារ និងថវិកា
- ➢ ជ្រើសរើសគ្រូសហគមន៍
- ➢ ចូលរួមក្នុងការគូរផែនទីសាលារៀនដើម្បីស្វែងរកធនធានមូលដ្ឋាន និងកុមារដែលមិនបានចូលសាលារៀន
- ➢ ត្រួតពិនិត្យតាមដានការងារផ្នែកបច្ចេកទេសឬរដ្ឋបាល
- ➢ ប្រមូលទិន្នន័យ
- ➢ រៀបចំកិច្ចសន្យាជាមួយគ្រូសហគមន៍
- ➢ រាយការណ៍ទៅប្រធានកម្រងសាលា
- ➢ កំណត់លក្ខណៈវិនិច្ឆ័យ(ពីរភាសា)ក្នុងការជ្រើសរើសគ្រូសហគមន៍
- ➢ កោះប្រជុំសមាជិកផ្សេងៗ